រស្មីកម្ពុជា

# ខណ្ឌមានជ័យ លើកកម្ពស់វិស័យអប់រំជាមួយដៃគូបណ្ដាអង្គការនានា

**ភ្នំពេញ** : បណ្ដាអង្គការ សមា- គម សហគមន៍នានា ជាដៃគូរបស់អាជ្ញាធរខណ្ឌមានជ័យ ត្រូវបំផុសទៅដល់ក្មួយៗជាសិស្សានុសិស្ស ត្រូវចូលរួមប្រមែប្រមូលសំរាមធ្វើអនាម័យ និងបរិស្ថានក្នុងសាលារៀន ដើម្បីលើកកម្ពស់សុខភាពយើងទាំងអស់គ្នា។ កាលណានៅសាលារៀន មានអនាម័យ និងបរិស្ថានល្អនោះ ក្មួយៗជាសិស្សានុសិស្ស មានចិត្តចង់មកសិក្សាដោយមិនគេចវេះពីសាលាដែរ ។

លោកគួច ចំរើន អភិបាលនៃគណៈអភិបាលខណ្ឌមានជ័យ មានប្រសាសន៍លើកឡើងបែបនេះ ខណៈចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងបញ្ចប់ការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ ដើម្បីលើកកម្ពស់វិស័យអប់រំ ។

កិច្ចប្រជុំនេះរៀបចំធ្វើឡើងដោយការិយាល័យអប់រំខណ្ឌមានជ័យ និងដៃគូជាច្រើន ហើយកិច្ចប្រជុំពិគ្រោះយោបល់នេះ ធ្វើឡើងពេញមួយថ្ងៃ ដោយមានភាគីខាងអង្គការ សមាគម សហគមន៍ ព្រមទាំងដៃគូជាច្រើនទៀតផងដែរ ។

ក្នុងកិច្ចប្រជុំនេះ ធ្វើបទបង្ហាញពីគម្រោងផែនការដែលត្រូវអនុវត្តនៅក្នុងអង្គការ សហគមន៍របស់ខ្លួន ដោយផ្ដោតទៅលើការជួយដល់កុមារក្រីក្រ និងបញ្ហាសុខភាព ព្រមទាំងការងារសង្គមជាច្រើនទៀតនៅខណ្ឌមានជ័យទាំងមូល ។

មានប្រសាសន៍នាឱកាសនោះ លោកគួច ចំរើន អភិបាលនៃគណៈអភិ-បាលខណ្ឌមានជ័យ បានលើកឡើងថា រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាខណ្ឌ សង្កាត់ និងអង្គការនានាជាដៃគូទាំងអស់ ធ្វើសកម្មភាពការងារជាគោលដៅរៀងៗខ្លួន ដើម្បីស៊ីសង្វាក់គ្នា និងផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ឱ្យបានដឹងរាល់សកម្មភាពរបស់ដៃគូក្នុងដែនដីរបស់ខ្លួន ។ លោកបន្តទៀតថា ជារួមអាជ្ញាធរចង់បានព័ត៌មានស្ដីពីលទ្ធផលការងារ ដើម្បីជួយលើកកម្ពស់លើវិស័យអប់រំនៅក្នុងខណ្ឌមានជ័យទាំងមូល ។

ជាមួយគ្នានេះ លោកគួច ចំរើន អភិបាលនៃគណៈអភិបាលខណ្ឌមានជ័យ ក៏បានថ្លែងកោតសរសើរទៅដល់លោកស្រីប្រធានការិយាល័យអប់រំខណ្ឌមានជ័យ គង់ កន្និឋា រួមជាមួយដៃគូអង្គការនានា ដែលបានខិតខំលើការងារនេះ ដោយធ្វើសកម្មភាពជួយដល់ប្រជាជនក្រីក្រ សិស្សានុសិស្ស និងបញ្ហាសុខភាព ព្រមទាំងការងារសង្គមផងដែរនៅក្នុងខណ្ឌ ។

ជាមួយគ្នានេះលោកគួច ចំរើន អភិបាលនៃគណៈអភិបាលខណ្ឌមាន-ជ័យក៏បានជូនលិខិតសរសើរប័ណ្ណសរសើរដល់បណ្ដាអង្គការរនានាជាដៃគូរបស់ខណ្ឌមានជ័យជាច្រើនរូប ដែលមានស្នាដៃចូលរួមលើការងារសង្គម ៕

**សុវណ្ណភូមិ**



*លោកគួច ចំរើន ចូលរួមបើកកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាង បញ្ចប់ការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤របស់ការិយាល័យអប់រំយុវជន-កីឡាខណ្ឌ(រូបៈសុវណ្ណភូមិ)*